# «សក្តានុពលនៃទំនាក់ទំនងសេដ្ឋកិច្ចកម្ពុជា-ចិន»



**សាស្ត្រាចារ្យបណ្ឌិត គី សេរីវឌ្ឍន៍**
**ប្រធានមជ្ឈមណ្ឌលសិក្សាចិន នៃរាជបណ្ឌិត្យសភាកម្ពុជា**

## ១-សេចក្តីផ្តើម

ផ្លូវនឹងខ្សែក្រវាត់ជាច្រកសេដ្ឋកិច្ចមួយ សំដៅលើប្រព័ន្ធនៃការដឹកជញ្ជូនទំនិញឬសេវាឆ្លងដែន ជាពិសេសសម្រាប់ប្រទេសដែលគ្មានផ្លូវសមុទ្រ។ ច្រកសេដ្ឋកិច្ចនេះ អាចធ្វើឡើងតាមរយៈផ្លូវជាតិឬតាមរយៈផ្លូវដែក ដែលអាចជំរុញកំណើនសេដ្ឋកិច្ចនៅតំបន់នៅជុំវិញផ្លូវនេះ។ ច្រកសេដ្ឋកិច្ចជាតំណភ្ជាប់ទាំងទំនាក់សេដ្ឋកិច្ច សង្គម វប្បធម៌ និងនយោបាយ ព្រមទាំងការបង្កើតសុខដុមនីយកម្មនៃប្រទេសក្បែរខាងឬប្រទេសស្ថិតក្នុងតំបន់តភ្ជាប់ច្រកសេដ្ឋកិច្ចនេះ។

ច្រកសេដ្ឋកិច្ចនេះ ត្រូវបានគេអនុវត្តច្រើនណាស់នៅលើពិភពលោក ជាពិសេសពីប្រទេសមួយទៅកាន់តំបន់ ឬសហគមន៍សេដ្ឋកិច្ចមួយ ដូចជា ការតភ្ជាប់ពីប្រទេសចិនមកកាន់សហគមន៍សេដ្ឋកិច្ចអាស៊ានតាមរយៈកម្ពុជា។ សក្តានុពលរបស់កម្ពុជាក្នុងតំបន់អាស៊ាន គឺជាប្រទេសផ្តល់នូវការអនុគ្រោះដល់វិស័យទេសចរណ៍ និងអាចក្លាយជាកន្លែងណាត់ជួបគ្នាដើម្បីកិច្ចការសេដ្ឋកិច្ច។ កម្ពុជាជាប្រទេសដែលមានការលូតលាស់សេដ្ឋកិច្ចយ៉ាងលឿន ដែលមានចំណូលសរុបកើនដល់ ២២,២ប៊ីលានដុល្លារ គិតតាមថ្លៃបច្ចុប្បន្ន ហើយប្រជាជនម្នាក់មានចំណូលជាមធ្យមប្រចាំឆ្នាំ១ ៤៣៤ដុល្លារ។ កម្ពុជាបានក្លាយជាសេដ្ឋកិច្ចខ្លា ដែលបានប្រសិទ្ធនាមដោយធនាគារពិភពលោក និងបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ

២០១៧។ ប្រទេសនេះ មានអត្រាកំណើនសេដ្ឋកិច្ចពិតថេរ៧%ក្នុងមួយឆ្នាំសម្រាប់រយៈពេល៥ឆ្នាំចុងក្រោយនេះ រួមទាំងអត្រាអតិផរណាទាបប្រហែល៣% ជាមធ្យមគិតត្រឹមឆ្នាំ២០១៦ និង ៣,៨% នៅឆ្នាំ២០១៧នេះ ។

វិយោគមានការកើនឡើងដល់ ៥,៨៨ប៊ីលានដុល្លារ ត្រូវជា ២៩,៤% នៃផលិតផលក្នុងស្រុកសរុប ក្នុងនោះវិនិយោគដែលបានមកពីវិស័យឯកជនចំនួន ៣ ៨៧៩លានដុល្លារនិង វិនិយោគមានមកពីរដ្ឋ ចំនួន ១ ៣៤៣លានដុល្លារ។

### ក្រាហ្វទី១៖ កំណើនចំណូលជាតិកម្ពុជា




## ២- ទំនាក់សេដ្ឋកិច្ចកម្ពុជា-ចិន

យោងតាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មកម្ពុជាពីឆ្នាំ២០១២-២០១៦ បានបង្ហាញថា រយៈពេល៥ឆ្នាំចុងក្រោយ ទំហំពាណិជ្ជកម្មកម្ពុជាបានកើនឡើងពី១៣ពាន់លានដុល្លារ នៅឆ្នាំ២០១២ រហូតដល់២២ពាន់លានដុល្លារនៅឆ្នាំ២០១៦ ដែលក្នុងនោះពាណិជ្ជកម្មជាមួយចិនមានប្រមាណជា២ ពាន់លានដុល្លារ(ឆ្នាំ២០១២) និងកើនដល់៥ពាន់លាន(ឆ្នាំ២០១៦) បើទោះបីជាមានឱនភាពពាណិជ្ជកម្មក៏ដោយ ក៏ទាំងការនាំចេញ(៥ពាន់លានដុល្លារឆ្នាំ២០១២ ដល់១០ពាន់លានដុល្លារឆ្នាំ២០១៦) និង ការនាំចូល(៧ពាន់លានដុល្លារឆ្នាំ២០១២ ដល់១២ពាន់លានដុល្លារឆ្នាំ២០១៦) គឺសុទ្ធតែមានកំណើន ជារៀងរាល់ឆ្នាំ។ កំណើនពាណិជ្ជកម្មកម្ពុជា-ចិនត្រូវបានគេមើលឃើញថាកើនលឿនជាងការរំពឹងទុក

របស់រាជរដ្ឋាភិបាលកម្ពុជាដែលមានបំណងនឹងបង្កើនទំហំពាណិជ្ជកម្មកម្ពុជា-ចិនឱ្យបានដល់៥ពាន់លានដុល្លារនៅឆ្នាំ២០១៧ (មើលក្រាហ្វិកទី២)។

## ក្រាហ្វទី២៖ ពាណិជ្ជកម្មកម្ពុជា




ទន្ទឹមនឹងនេះដែរ កម្ពុជាបាននាំចេញទៅចិនក្នុងទំហំទឹកប្រាក់ប្រមាណជា១៧៨លានដុលារ ក្នុងឆ្នាំ២០១២ ហើយកើនឡើងដល់៦០៩លានដុល្លារនៅឆ្នាំ២០១៦។ ការនាំចេញរបស់កម្ពុជាទៅចិនមានកំណើនប្រហែលជា៥០ភាគរយ និងការនាំចូលពីប្រទេសចិនកើនឡើងប្រមាណជា១៦ភាគរយធៀបទៅនិងឆ្នាំ២០១៥(មើលក្រាហ្វិកទី៣)។

## ក្រាហ្វទី៣៖ ពាណិជ្ជកម្មកម្ពុជាចិន



ទំនិញដែលកម្ពុជានាំចូលច្រើនជាងគេរួមមានវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់ដល់ឧស្សាហកម្មសម្លៀកបំពាក់ រថយន្ត និងផលិតផលប្រេងឥន្ធនៈ ហើយចិនជាអ្នកផ្គត់ផ្គង់ទំនិញធំបំផុតដល់កម្ពុជា ដែលបានកើនឡើងដល់១៦% គិតជាទឹកប្រាក់ប្រមាណជា៤,៥៣ន់លានដុល្លារធៀបនឹងឆ្នាំ២០១៥។ នៅឆ្នាំ២០១៧ ការនាំចូលទំនិញពីប្រទេសចិនមានការកើនឡើងដល់៥,២៨៧លានដុល្លារ។ ចំណែកឯការនាំចេញទៅប្រទេសចិនវិញ នៅឆ្នាំ២០១៦ កម្ពុជានាំចេញទៅចិនក្នុងទឹកប្រាក់៦០៩លានដុល្លារ ហើយការនាំចេញនេះមានកំណើនរហូតដល់ទៅ២៣,៦៥% នៅឆ្នាំ២០១៧ ក្នុងទឹកប្រាក់៧៥៣លានដុល្លារ។

ចំពោះការនាំចេញអង្ករទៅប្រទេសចិននៅឆ្នាំ២០១៧ មានចំនួ២១៥,១៥៥តោន គឺមានការកើន៦៨% ធៀបនឹងឆ្នាំ២០១៦។

លើសពីនេះទៀតកម្ពុជានិងចិនបានបង្កើតតំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្មជាច្រើននៅក្នុងខេត្តព្រះសីហនុ។ ចំនួនអ្នកវិនិយោគចិនចូលមកកម្ពុជាកាន់តែច្រើនរួមទាំងភ្ញៀវទេសចរ ដោយសារគោលនយោបាយ China Ready របស់កម្ពុជា ដើម្បីស្រូបទាញភ្ញៀវចិនឱ្យបាន២លាននាក់នៅឆ្នាំ២០២០។

វិនិយោគរបស់ចិនមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាប្រភពទុនដ៏ធំសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។ នៅឆ្នាំ២០១៦ ការវិនិយោគសរុបរបស់ចិនមានចំនួន ១ ០៨០លានដុល្លារអាម៉េរិក ហើយនៅឆ្នាំ២០១៧ បានកើនឡើង៥២% ត្រូវជា១ ៦៤៤លានដុល្លារ។ ចំពោះឆ្នាំ២០១៨ គិតត្រឹមខែមិថុនា វិនិយោគទុនចិនជាប់ចំណាត់ថ្នាក់លេខ១ ក្នុងចំណោមវិនិយោគទុនបរទេសទាំងអស់។

ចំពោះវិស័យអគ្គិសនីវិញ កម្ពុជាបានកសាងវារិអគ្គិសនីចំនួន៧កន្លែង ក្រោមកិច្ចសហប្រតិបត្តិការជាមួយចិន ដូចជា គិរីរម្យទី១ គិរីរម្យទី៣ កំចាយ អាតៃ ឫស្សីជ្រុំ តាតៃ សេសានក្រោម២ ដែលផ្គត់ផ្គង់អគ្គិសនីសរុបចំនួន១ ៣៨២,១ មេហ្គាវ៉ាត់ ក្នុងទឹកប្រាក់សរុប២ ៣៧០,៨៩លានដុល្លារអាម៉េរិក។

**តារាងទី១៖ វិនិយោគផ្ទាល់ពីចិន**

| | កសិកម្ម | រ៉ែ | កម្មន្តសាល | ហិរញ្ញវត្ថុ | សណ្ឋាគារ | ICT | អចលនទ្រព្យ | ផ្សេងៗ | Total |
|---|---|---|---|---|---|---|---|---|---|
| China Mainland | 53 | 15 | 163 | 83 | 62 | 10 | 75 | 50 | 511 |
| Hong Kong | 10 | 2 | 43 | 16 | 31 | 0 | 61 | 74 | 237 |
| Taiwan | 0 | 0 | 45 | 33 | 0 | 0 | 19 | 8 | 105 |
| Total | 63 | 17 | 251 | 132 | 93 | 10 | 155 | 132 | 853 |
| **Percentage** | **27.16%** | **89.47%** | **64.36%** | **24.49%** | **40.79%** | **66.67%** | **41.89%** | **47.48%** | **39.58%** |

(ប្រភព៖ ធនាគារជាតិនៃកម្ពុជា (២០១៧) របាយការណ៍ប្រចាំឆ្នាំ២០១៧)

## ក្រាហ្វទី៤៖ ទេសចរណ៍កម្ពុជាពឹងផ្អែកលើអង្គរវត្ត




(ប្រភព៖ អាជ្ញាធរអប្សរា)

វិស័យទេសចរណ៍ ដែលឆ្លុះបញ្ចាំងតាមរយៈចំនួនភ្ញៀវទេសចរ មានកំណើនប្រហាក់ប្រហែលនឹងឆ្នាំ២០១៥ ក្នុងរង្វង់៦% ប៉ុន្តែធៀបនឹងនិន្នាការមុនឆ្នាំ២០១៤ កំណើននេះមានអត្រាថយចុះដោយសារការឡើងថ្លៃប្រាក់ដុល្លារ ដែលធ្វើឱ្យចំណាយរបស់ភ្ញៀវទេសចរបានកើនខ្ពស់ជាងមុនគួបផ្សំនឹងកង្វះពិពិធកម្មគោលដៅទេសចរណ៍។ ទីផ្សារទេសចរធំជាងគេរបស់កម្ពុជាគឺ វៀតណាម (២០%នៃភ្ញៀវទេសចរសរុប) បន្ទាប់មកគឺចិន (១៧%) កូរ៉េ (៨%) និង ថៃ (៧%)។

## តារាងទី២៖ កំណើនសេវាកម្មសម្រាប់វិស័យទេសចរណ៍

| វិស័យ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ប៉ាន់ | ២០១៧ព្យ. |
|---|---|---|---|---|---|---|---|
| សេវាកម្ម | ៥,០ | ៨,១ | ៨,៧ | ៨,៧ | ៧,១ | ៦,៧ | ៦,៨ |
| *សណ្ឋាគារ និង ភោជនីយដ្ឋាន* | *៦,៦* | *១២,៥* | *១៣,៨* | *៦,១* | *២,៤* | *២,២* | *៣,០* |
| *អនុវិស័យសេវាកម្មផ្សេងទៀត* | *៤,៨* | *៧,៥* | *៧,៩* | *៩,២* | *៧,៨* | *៧,៤* | *៧,៤* |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ, ២០១៦

សម្គាល់: ២០១៦ និង ២០១៧ ជាការព្យាកររបស់ក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ China Ready ក្នុងបំណងទាក់ទាញភ្ញៀវទេសចរចិនឱ្យបាន២លាននាក់នៅឆ្នាំ២០១០។ រហូតមកដល់ឆ្នាំ២០១៧នេះ ភ្ញៀវទេសចរចិនបានកើនឡើងដល់១.២លាននាក់ហើយ។

## ក្រាហ្វទី៥៖ ចំនួនភ្ញៀវទេសចរចិនមកកម្ពុជា




(ប្រភព៖ គី សេរីវឌ្ឍន៍ (២០១៨) របាយការណ៍ប្រទេសកម្ពុជាឆ្នាំ២០១៧ នៅទីក្រុងប៉េកាំង)

## ក្រាហ្វទី៦៖ ប្រភពកម្ចីរបស់រដ្ឋាភិបាលកម្ពុជា




(ប្រភព៖ ធនាគារជាតិនៃកម្ពុជា)

## ក្រាហ្វទី៥៖ កម្ចីសម្បទានពីរដ្ឋាភិបាលចិន




(ប្រភព៖ គី សេរីវឌ្ឍន៍ (២០១៨) របាយការណ៍ប្រទេសកម្ពុជាឆ្នាំ២០១៧ នៅទីក្រុងប៉េកាំង)

## តារាងទី៣៖ តំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

| *Location* | *Name* | *Year* | *Projects* | *Investment (USD m.)* | *Empl.* |
|---|---|---|---|---|---|
| Phnom Penh | Phnom Penh SEZ | 2006 | 89 | 555 | 16 945 |
| Svay Rieng | Kerry Worldbridge SEZ | 2015 | 1 | 21 | 25 |
| | Manhattan SEZ | 2006 | 31 | 128 | 27 071 |
| | Tai Seng Bavet SEZ | 2007 | 27 | 154 | 9 238 |
| | Dragon King SEZ | 2012 | 4 | 19 | 1 175 |
| | Shandong Sunshell SEZ | 2013 | 5 | 15 | 5 571 |
| Sihanoukville | Hi-Park SEZ | 2013 | 1 | 3 | 159 |
| | Qi Lu (Jian Pu Zhai) SEZ | 2017 | 1 | 1 | 16 |
| | Sihanoukville SEZ 2 | 2008 | 109 | 313 | 14 874 |
| | Sihanoukville SEZ 1 | 2006 | 3 | 998 | 652 |
| | Sihanoukville Port SEZ | 2009 | 3 | 22 | 857 |
| Poipet | Poi Pet O'Neang SEZ | 2006 | 5 | 8 | 1 612 |
| | Sanco Poi Pet SEZ | 2013 | 10 | 69 | 1 298 |
| Koh Kong | Neang Kok Koh Kong SEZ | 2007 | 5 | 67 | 7 899 |
| Kandal | Goldfame Paksun SEZ | 2007 | 2 | 26 | 4 606 |
| | Suvannaphum | 2014 | 1 | 1.5 | 39 |
| **TOTAL** | | | **297** | **2 400** | **92 037** |

Source : CDC, CSEZB http://www.cambodiainvestment.gov.kh/list-of-SEZ.html

តំបន់សេដ្ឋកិច្ចពិសេសកម្ពុជាមានសរុប១៧តំបន់ ក្នុងមាន៥តំបន់ជាតំបន់សេដ្ឋកិច្ចពិសេសចិន ដែលមាននៅខេត្តព្រះសីហនុ៣តំបន់និងខេត្តស្វាយរៀងចំនួន២តំបន់។ក្នុងតំបន់សេដ្ឋកិច្ចពិសេសចិននោះ មានប្រតិបត្តិការលើគម្រោងចំនួន១២៣គម្រោងក្នុងទឹកប្រាក់១,៣៤៩លានដុល្លារ។

## ៣- ច្រកសេដ្ឋកិច្ចកម្ពុជាចិន

ចាប់តាំងពីឆ្នាំ១៩៨៩ កម្ពុជាបានសិក្សាលើគន្លងនៃការផ្លាស់ប្តូរមករកសេដ្ឋកិច្ចទីផ្សារសេរីពីគំរូរបស់ចិនដោយធ្វើមានឯកជនភាវូបនីយកម្ម មានកម្មសិទ្ធិឯកជននិងដកចេញនូវការគ្រប់គ្រងថ្លៃ។ ក្រោយមកកម្ពុជាបានចូលជាសមាជិកសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់អាស៊ាន នៅឆ្នាំ១៩៩៩ ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤ និងចូលរួមបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅចុងឆ្នាំ២០១៥ព្រមទាំងបានរឹតចំណងសេដ្ឋកិច្ចពាណិជ្ជកម្មជាមួយបណ្តាប្រទេសនានាជាពិសេសប្រទេសអាស៊ានបូកមួយ អាស៊ានបូក៣ និង អាស៊ានបូក៦។

កម្ពុជាបានបើកច្រកសេដ្ឋកិច្ចរបស់ខ្លួនមិនត្រឹមតែអាស៊ានទេ គឺឈានដល់បើកច្រកទីផ្សារគ្មានពន្ធគយនិងកូតា រហូតដល់ជាង៩៧%នៃប្រទេសអភិវឌ្ឍន៍ និង ទទួលបានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មឯកតោភាគីរហូតដល់៣២ប្រទេស ជាពិសេសទទួលបានប្រព័ន្ធអនុគ្រោះលើមុខទំនិញគ្រប់មុខលើកលែងសព្វាវុធពីសហគមន៍អឺរ៉ុប។

កម្ពុជាមានទីតាំងភូមិសាស្ត្រស្ថិតនៅចំកណ្តាលនៃប្រទេសអាស៊ាន ដែលមានសក្តានុពលខ្ពស់ក្នុងការបែងចែកទំនិញ ដែលមានច្រកបង្ហូរជាច្រើនទៅប្រទេសអាស៊ានតាមផ្លូវគោក ផ្លូវដែក និង ផ្លូវសមុទ្រ ដែលទំហំទីផ្សារមានចំនួនប្រជាជនដល់ទៅ៦០០លាននាក់។

កម្ពុជាមិនមាននិន្នាការនយោបាយភូមិសាស្ត្រលម្អៀងទៅរកមហាអំណាចមួយណាទេ ជាគោលនយោបាយអព្យាក្រឹតមិនចូលបក្សសម្ព័ន្ធតាំងពីសម័យសង្គ្រាមត្រជាក់មកម្លេះ ដូច្នេះកម្ពុជាមានបងប្អូនជាច្រើនដែលជាបណ្តាប្រទេសសមាជិកអាស៊ាន ដែលកម្ពុជាជាសំឡេងមួយសម្រាប់កំណត់ដោគវាសនាអាស៊ានដែលឈរលើគោលនយោបាយមតិឯកច្ឆន្ទ (កុងសង់ស៊ុស)។

តាមគោលការណ៍នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ប្រទេសជាសមាជិកទាំងអស់ត្រូវរៀបចំប្រព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនដើម្បីបន្សុីចូលទៅក្នុងសមាហរណកម្ម សេដ្ឋកិច្ចអាស៊ានឱ្យកាន់តែស៊ីជម្រៅ បើកចំហរសេដ្ឋកិច្ច ដោយរៀបចំជាទីផ្សារនិងមូលដ្ឋានផលិតកម្មអាស៊ានរួមមួយ។ ដើម្បីសម្រេចបាននូវសមាហរណកម្មនេះ យន្តការនៃការអនុវត្តសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗត្រូវតែមានភាពប្រកួតប្រជែង និងប្រកប

ដោយថាមភាពក្នុងការបង្កើនល្បឿនសមាហរណកម្មលើវិស័យអាទិភាព សម្របសម្រួលដល់លំហូរអ្នកជំនួញ ក៏ដូចជាកម្លាំងពលកម្មជំនាញនិងភាពប៉ិនប្រសប់។

ជាមួយគ្នាដែរ កម្ពុជាត្រូវបានផ្តល់នូវកិច្ចសហប្រតិបត្តិការលើវិស័យធនធានមនុស្ស ការកសាងសមត្ថភាព ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យា គោលនយោបាយហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ពិសេសពាណិជ្ជ-កម្មអន្តរជាតិ ដើម្បីឈានទៅដល់សមភាពក្នុងការអភិវឌ្ឍនៃបណ្តាប្រទេសសមាជិកអាស៊ាន។

## ក្រាហ្វទី៤៖ ពាណិជ្ជកម្មក្នុងតំបន់អាស៊ាន




ក្រៅពីពាណិជ្ជកម្ម កម្ពុជានិងចិនជាដៃគូល្អក្នុងដំណើរការនយោបាយការបរទេស ដោយកម្ពុជាបានគាំទ្រចិនលើគោលនយោបាយ«ចិនតែមួយ»។ ក្នុងទំនាស់បញ្ហាសមុទ្រចិនខាងត្បូង កម្ពុជាបានស្នើឱ្យអាស៊ានដាក់ឱ្យដោះស្រាយតាមវិធាន COC។ កម្ពុជាប្រកាន់ជំហរអព្យាក្រឹតមិនលម្អៀងទៅខាងភាគីណាឡើយ តែផ្តល់សារៈសំខាន់លើការរក្សាសន្តិភាព សន្តិសុខ និង ស្ថិរភាពផ្លូវសមុទ្រ។

## ៤- សន្និដ្ឋាន

សុខដុមនីយកម្មតំបន់គឺជាគោលដៅរបស់ច្រកសេដ្ឋកិច្ច។ កម្ពុជាចិនអាចបង្កើតច្រកសេដ្ឋកិច្ចមួយដ៏ល្អមួយបានតាមរយៈសក្តានុពលសេដ្ឋកិច្ចរបស់កម្ពុជាក្នុងតំបន់អាស៊ាន ដែលរបាំងពន្ធគយលើទំនិញប្រើប្រាស់មួយចំនួនត្រូវធ្លាក់ដល់សូន្យ។ ទោះជាយ៉ាងណា ឥរិយាបថនៃទំនាក់ទំនងកម្ពុជា ចិនក្នុងក្រសែភ្នែកមហាជនហាក់ដូចជានៅមានកម្រិត។ ខ្ញុំជឿថា ការបង្កើតនូវវិបុលភាពសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ

ដោយជំរុញមានកិច្ចសហការដោយស្មើភាពគ្នារវាងកម្ពុជា ក៏ជាមធ្យោបាយមួយជួយលើកទឹកចិត្តដល់ការបើកច្រកសេដ្ឋកិច្ចដែរ។ ទី២កម្ពុជាត្រូវការប្រភពទុនវិនិយោគយ៉ាងច្រើនសម្រាប់កសាងនូវហេដ្ឋារចនាសម្ព័ន្ធនៃច្រកសេដ្ឋកិច្ចទាំងនេះ។

## គន្ថនិទ្ទេស


1. ក្រសួងការងារ (២០១៧) សមិទ្ធិផលការងារ ២០០៨-២០១៧ ភ្នំពេញ កម្ពុជា
2. ក្រសួងកសិកម្ម (២០១៧) របាយការណ៍បូកសរុបលទ្ធផល ២០១៦ ភ្នំពេញ កម្ពុជា
3. ក្រសួងឧស្សាហកម្ម (២០១៥) គោលនយោនបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ ភ្នំពេញកម្ពុជា
4. ប៉ាន សូរស័ក្តិ (២០១៧) បទបង្ហាញក្នុងកិច្ចពិភាក្សាស្តីពី មាគ៌ាដ៏ត្រឹមត្រូវសម្រាប់កម្ពុជាដើម្បីរក្សាសន្តិភាព និង ឆ្ពោះទៅរកការអភិវឌ្ឍ
5. សហគមន៍សេដ្ឋកិច្ចអាស៊ាន (២០១៥) Asean Economic Community Blueprint 2025, Jakarta
6. សហគមន៍សេដ្ឋកិច្ចអាស៊ាន (២០១៧) Toward Asean Economic Community 2025, Jakarta
7. គី សេរីវឌ្ឍន៍ (២០១៨) របាយការណ៍ប្រទេសកម្ពុជាឆ្នាំ២០១៧ ក្នុងសិក្ខាសាលាស្តីពី គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចសម្រាប់ប្រទេសកំពង់អភិវឌ្ឍន៍ ខែមេសា ឆ្នាំ២០១៨
8. ធនាគារជាតិនៃកម្ពុជា (២០១៧) របាយការណ៍ប្រចាំឆ្នាំ២០១៧
9. គេហទំព័រក្រសួងកសិកម្ម http://www.maff.gov.kh